ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៧៤០៣ កសក

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៣

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ជាទីគោរពដ៏ខ្ពង់ខ្ពស់

**__កម្មវត្ថុ__** ៖ របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៣ និងល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤។

**__យោង__** ៖ ចំណារដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅលើលិខិតលេខ៣៦ ពស គ.ជ.គ.ម ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៣ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៣-២០១៤ គិតត្រឹមថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០១៣ មានដូចតទៅ ៖

### I- __សភាពការណ៍រួម__ ៖

ក្នុងសប្តាហ៍ទី៣ នៃខែវិច្ឆិកា ស្ថានភាពអាកាសធាតុទទួលរងឥទ្ធិពលពីជ្រលងសម្ពាធទាបខ្យល់បក់មកពីទិសឦសាន ផ្ទៃមេឃមានពពកពីតិចទៅមធ្យម អាចនិងមានភ្លៀងធ្លាក់តិចតួចនៅតាមតំបន់នៃរាជធានីខេត្ត។ ជាមួយនោះ ប្រជាកសិករបានខិតខំជំរុញការងារប្រមូលផលដំណាំ ជាពិសេសដំណាំស្រូវរដូវវស្សានាពេលនេះប្រមូលផលបាន ២១,៣៥% នៃផ្ទៃដីអនុវត្ត។ ទន្ទឹមនឹងនោះ ប្រជាកសិករបាននឹងកំពុងជំរុញដំណើរការការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៣-២០១៤ ក្នុងនោះ ដំណាំស្រូវសម្រេចបាន ១៧,០៨% នៃផែនការដាំដុះ។

### II- __ល្បឿនការងារប្រមូលផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣__ ៖ (ដូចមានតារាងជូនភ្ជាប់)

គិតមកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីសរុបចំនួន **៥៤៧.១៤២ហាត** ដោយទទួលបានបរិមាណផលសរុបចំនួន១.៦៨៤.៩១៩តោន មានទិន្នផលជាមធ្យមចំនួន៣,០៧៩តោន/ហាត។

### III- __ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិឆ្នាំ២០១៣__ ៖ (ដូចមានតារាងជូនភ្ជាប់)

រដូវវស្សាឆ្នាំ២០១៣នេះ ភ្លៀងធ្លាក់ពីដើមរដូវបង្កភាពងាយស្រួលដល់ការងារបង្កបង្កើនផល ទន្ទឹមនឹងនោះ ក៏បានជួបគ្រោះធម្មជាតិ (រាំងស្ងួតនិងទឹកជំនន់) បានបង្កឲ្យមានផលប៉ះពាល់ និងខូចខាតដំណាំស្រូវរដូវវស្សាដូចខាងក្រោម៖

**ក.__ប៉ះពាល់និងខូចខាតដោយកង្វះខាតទឹក__**

- ប៉ះពាល់លើសំណាបសរុបចំនួន ៦៣១ហាត ក្នុងនោះខូចខាតចំនួន ២៥០ហាត
- ប៉ះពាល់លើសន្ទូង-ពង្រោះចំនួន ៩.៩៩៧ហាត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ខ.ប៉ះពាល់និងខូចខាតដោយទឹកជំនន់

- ប៉ះពាល់លើសំណាបចំនួន **១២០ហត** ក្នុងនោះខូចខាតចំនួន **៨២ហត**
- ប៉ះពាល់លើសន្ទូង-ពង្រោះចំនួន **៣៧៨.៥៧២ហត** ក្នុងនោះខូចខាតចំនួន **១២៨.៤២១ហត**។

គ.លទ្ធភាពស្តារនិងផ្ទៃដីស្តារបានជាក់ស្តែងលើសន្ទូង-ពង្រោះ

- ផ្ទៃដីលទ្ធភាពស្តារចំនួន **៥៧.៩៨២ហត**
- ផ្ទៃដីស្តារបានជាក់ស្តែងចំនួន **២៦.៣៩១ហត**។

អនុវត្តតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការបែងចែកពូជស្រូវ សម្រាប់ស្តារការខូចខាតជូនដល់ប្រជាកសិករនៅតាមបណ្តាខេត្តមួយចំនួនដូចជា៖

១. **ខេត្តបាត់ដំបង** មន្ទីរកសិកម្មបានផ្តល់ពូជស្រូវដល់ប្រជាកសិករចំនួន **៦៩ តោន** នៅស្រុកបវេល ថ្មគោល ឯកភ្នំ រុក្ខគិរី និងគាស់ក្រឡ។ មន្ទីរកសិកម្មនឹងបន្តផ្តល់ពូជស្រូវជូនដល់ប្រជាកសិករជាបណ្តើរ បន្ថែមទៀត

២. **ខេត្តកណ្តាល**: បានផ្តល់ពូជស្រូវអំណោយរបស់អង្គការការីតាសដល់ប្រជាកសិករចំនួន **២៩ តោន** នៅស្រុកពញាឮលើផ្ទៃដីចំនួន**១៥៥ហត** (ដាំដុះស្រូវប្រដេញទឹក) និងស្អាងលើផ្ទៃដីសរុបចំនួន៨៥ហត។ ដោយឡែកផ្ទៃដីខូចខាតចំនួន **៦២៥ហត** នៅស្រុកខ្សាច់កណ្តាល ប្រជាកសិករបានស្តារឡើងវិញរួចរាល់អស់ហើយ ដោយប្រើប្រាស់ពូជស្រូវដែលពួកគាត់មានស្រាប់

៣. **ខេត្តព្រៃវែង**: បានផ្តល់ពូជស្រូវដល់ប្រជាកសិករចំនួន **៧៦,៩៥០ តោន** ក្នុងនោះ

- ពូជស្រូវរបស់មន្ទីរកសិកម្មផ្តល់ជូនប្រជាកសិករចំនួន **៣៧តោន** នៅស្រុកពារាំងចំនួន ១២តោន បាភ្នំចំនួន ១៥តោន និងស្វាយអន្ទរចំនួន ១០តោន
- ពូជស្រូវអំណោយរបស់អង្គការការីតាសផ្តល់ជូនប្រជាកសិករចំនួន **៣០តោន** នៅស្រុកពារាំងចំនួន ១០តោន ពោធិ៍រៀងចំនួន ១០តោន និងស៊ីធរកណ្តាលចំនួន ១០តោន
- ពូជស្រូវអំណោយរបស់អង្គការ AOC ផ្តល់ជូនប្រជាកសិករចំនួន **៩,៩៥០តោន** នៅស្រុកពារាំង។

សម្រាប់ខេត្តព្រៃវែងបានស្តារជាក់ស្តែងលើផ្ទៃដីដំណាំស្រូវសរុបចំនួន **១៣.១២២ហត** ក្នុងនោះ មន្ទីរកសិកម្មបានអន្តរាគមន៍ផ្តល់ជាសំណាបដាប៉ុកនិងជួយជាកម្លាំងស្ទូងសម្រេចបានលើផ្ទៃដីសរុបចំនួន**៨៦២ហត** បន្ថែមលើស្រូវពូជដែលបានផ្តល់ជូនកសិករ។ ជាមួយនោះ អគ្គនាយកដ្ឋានកសិកម្មបានផ្តល់នូវពូជបន្លែចំរុះចំនួន១០០កញ្ចប់ ជូនដល់ប្រជាកសិករនៅស្រុកបាភ្នំ ពាមរក៍ និងកំពង់ត្របែក។

## IV- ល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំង២០១៣-២០១៤ ៖ (ដូចមានតារាងជូនភ្ជាប់)

ក.ដំណាំស្រូវ

-លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន១៦២.០៨៩ ហត លើសឆ្នាំមុនចំនួន ៥៥.៧០៦ហត

-សាបបានចំនួន ១.៤១១ហត តិចជាងឆ្នាំមុនចំនួន ៦៧៥ហត

-សន្ទូងនិងព្រោះសម្រេចបានចំនួន ៦៥.៧៩៥ហត ស្មើនឹង១៧,០៨ភាគរយ នៃផែនការ ៣៧៨.៩៩០ហត តិចជាងឆ្នាំមុន២២.៣១៦ហត។

ខ.ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំអនុវត្តបាន ៣.៧៧៨ហាត ស្មើនឹង ៨,៦០ភាគរយ នៃផែនការ ៤៣.៩៤៨ហាត តិចជាងឆ្នាំមុន ៩៧៥ហាត ក្នុងនោះ ៖

+ ពោតសរុបចំនួន ៧៦៥ហាត (ក្នុងនោះពោតក្រហម ១.០៧២ហាត) តិចជាងឆ្នាំមុន១.១៩៣ហាត

+ ដំឡូងឈើចំនួន ៣២ហាត លើសឆ្នាំមុន ២៦ហាត

+ ដំឡូងជ្វាសរុបចំនួន ១៦៨ហាត តិចជាងឆ្នាំមុន ៩៨ហាត

+ បន្លែគ្រប់មុខសរុបបាន ១.៥០៩ហាត លើសឆ្នាំមុន ៦៣១ហាត

+ សណ្តែកបាយសរុបបាន ១.៣០៤ហាត តិចជាងឆ្នាំមុន ៣៤១ហាត។

- ផ្ទៃដីដំណាំឧស្សាហកម្មអនុវត្តបានចំនួន ១.៤១៩ហាត ស្មើនឹង ៧,០៨ភាគរយ នៃផែនការ ២០.០៤៤ហាត លើសឆ្នាំមុន ១.១២១ហាត ក្នុងនោះ ៖

+ សណ្តែកដីសរុបបាន ៤៣៦ហាត លើសឆ្នាំមុន ២២១ហាត

+ ល្ងសរុបបាន ៦ហាត លើសឆ្នាំមុន ៦ហាត

+ អំពៅសរុបបាន ១១៣ហាត លើសឆ្នាំមុន ៣០ហាត

+ ថ្នាំជក់សរុបបាន ៨៦៤ហាត លើសឆ្នាំមុន ៨៦៤ហាត។

V- **សន្និដ្ឋាន៖** ជារួមការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៣ គិតមកទល់សប្តាហ៍នេះ ប្រជាកសិករបាននិងកំពុងខិតខំជំរុញការងារប្រមូលផលស្រូវវស្សានិងស្តារផ្ទៃដីខូចខាតដែលទទួលរងនូវគ្រោះធម្មជាតិហើយនិងការដាំដុះនាដូវប្រាំងបន្តទៀត។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការខិតខំថែទាំដំណាំស្រូវ និងយកចិត្តទុកដាក់លើការគ្រប់គ្រង និងការប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាព ក៏ដូចជាការថែទាំដំណាំផ្សេងៗ និងរក្សាទឹកទុកឲ្យបានគត់មត់នៅចុងរដូវ។

អាស្រ័យហេតុដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

រដ្ឋមន្ត្រី
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ឹក រ៉ាប៊ុន**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមថ្នាក់ដឹកនាំក្រសួង "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ